ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៧ សហវ.ប្រក.ចបថ

# ប្រកាស
## ស្តីពី
## វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិកានៅផ្ទៃក្នុងជំពូក និងផ្ទៃក្នុងកម្មវិធី និងការបន្ថែមឥណទានថវិកា សម្រាប់ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច
# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីវិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិកានៅផ្ទៃក្នុងជំពូក និងផ្ទៃក្នុងកម្មវិធី និងការបន្ថែមឥណទានថវិកា សម្រាប់ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ៣.-**

កិច្ចប្រតិបត្តិការបង្វែរឥណទានថវិកានៅផ្ទៃក្នុងជំពូក និងផ្ទៃក្នុងកម្មវិធី និងការបន្ថែមឥណទានថវិកា ត្រូវអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

វិធាន និងនីតិវិធីក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការបង្វែរឥណទានថវិកានៅផ្ទៃក្នុងជំពូក និងផ្ទៃក្នុងកម្មវិធី និងការបន្ថែមឥណទានថវិកា សម្រាប់ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ត្រូវកំណត់ដោយបទដ្ឋានគតិយុត្តរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី ២
# វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិការបស់រដ្ឋបាលកណ្តាលនៃក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល

## ផ្នែកទី ១
## វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិកាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ប្រការ៤.-**

ការបង្វែរឥណទានថវិកាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

- ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ
- ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ
- ការបង្វែរឥណទានថវិការវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត
- ដោយឡែក ជំពូក ៦៤ (ចំណាយបន្ទុកបុគ្គលិក) មិនត្រូវបានអនុញ្ញាតឱ្យបង្វែរឥណទានថវិកាចេញទៅជំពូកផ្សេងឡើយ

នីតិវិធីនៃការស្នើសុំបង្វែរឥណទានថវិកាខាងលើ អង្គភាពថវិកាត្រូវរៀបចំការស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយត្រូវឆ្លងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ។

## ផ្នែកទី ២
## វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិកាកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួង ឬដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល

**ប្រការ៥._**

ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវបានប្រតិភូកម្មអំណាចក្នុងការបង្វែរឥណទានថវិកា ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

- ការបង្វែរឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយក្នុងគណនីតែមួយ និងក្នុងកម្មវិធីតែមួយ
- ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងក្នុងចង្កោមសកម្មភាពតែមួយ

ការបង្វែរឥណទានថវិកាខាងលើ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាមី ឬដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល លើកលែងតែមុខចំណាយមួយចំនួនដែលមានហានិភ័យក្នុងការគ្រប់គ្រងថវិកា ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។

នីតិវិធីនៃការស្នើសុំបង្វែរឥណទានថវិកាខាងលើ អង្គភាពថវិកាត្រូវរៀបចំការស្នើសុំមករដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដោយត្រូវចម្លងប្រកាស ឬសេចក្តីសម្រេចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ)។

## ជំពូកទី ៣
## វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន

## ផ្នែកទី ១
## វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិកាត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ប្រការ៦._**

ការបង្វែរឥណទានថវិកាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

- ការបង្វែរឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយក្នុងគណនីតែមួយ និងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ
- ការបង្វែរឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយក្នុងគណនីតែមួយ និងពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ
- ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ

- ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ

នីតិវិធីនៃការស្នើសុំបង្វែរឥណទានថវិកាខាងលើ មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័នត្រូវរៀបចំការស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

## ផ្នែកទី ២
## វិធាន និងនីតិវិធីនៃការបង្វែរឥណទានថវិកាកំណត់ដោយសេចក្ដីសម្រេចរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

**ប្រការ៧._**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវបានប្រតិភូកម្មអំណាចក្នុងការផ្ដល់ការឯកភាពលើការស្នើសុំបង្វែរឥណទានថវិកា ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

- ការបង្វែរឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយក្នុងគណនីតែមួយ និងក្នុងចង្កោមសកម្មភាពតែមួយ
- ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងក្នុងចង្កោមសកម្មភាពតែមួយ

ការបង្វែរឥណទានថវិកាខាងលើ ត្រូវធ្វើឡើងដោយសេចក្ដីសម្រេចរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត លើកលែងតែមុខចំណាយមួយចំនួនដែលមានហានិភ័យក្នុងការគ្រប់គ្រងថវិកា ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។

នីតិវិធីនៃការស្នើសុំបង្វែរឥណទានថវិកាខាងលើ មន្ទីរជំនាញរាជធានី ខេត្តនៃក្រសួង ស្ថាប័ន ត្រូវរៀបចំការស្នើសុំមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយត្រូវចម្លងសេចក្ដីសម្រេចជូនរតនាគាររាជធានី ខេត្ត។

## ជំពូកទី ៤
## វិធាន និងនីតិវិធីនៃការបន្ថែមឥណទានថវិកា កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ប្រការ៨._**

ការបន្ថែមឥណទានថវិកា ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតលើមុខសញ្ញាចំណាយ ដូចខាងក្រោម៖

- បន្ទុកបុគ្គលិក
- បំណុលសាធារណៈ
- វិភាគទានសមាជិកភាពចំពោះស្ថាប័នអន្តរជាតិឬអន្តររដ្ឋាភិបាល
- អន្តរាគមន៍គាំពារសង្គម និង
- ចំណាយផ្សេងទៀត ដែលមានចរិតជាចំណាយបន្ទុកបុគ្គលិក។

នីតិវិធីនៃការស្នើសុំបន្ថែមឥណទានថវិកាខាងលើ អង្គភាពថវិកានៃក្រសួង ស្ថាប័នសាមីត្រូវរៀបចំការស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយត្រូវឆ្លងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ។

នីតិវិធីនៃការស្នើសុំបន្ថែមឥណទានថវិកាខាងលើ មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័នត្រូវរៀបចំការស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

## ជំពូកទី ៥
## កំហិតកំណត់នៃប្រតិភូកម្មអំណាចក្នុងការបង្វែរឥណទានថវិកា

**ប្រការ៩._**

ប្រតិភូកម្មសិទ្ធិអំណាចដែលបានផ្តល់ជូនខាងលើដល់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ឬប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការបង្វែរឥណទានថវិការបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្តនៃក្រសួង ស្ថាប័ន មិនត្រូវបានអនុញ្ញាតលើអនុគណនីមួយចំនួន ដូចខាងក្រោម៖

- ជំពូក ៦៤ (បន្ទុកបុគ្គលិក)
  - ៦៤០២៣: ប្រាក់បំណាច់ម៉ោងបន្ថែម
  - ៦៤០២៥: ប្រាក់បំប៉នជីវភាពពិសេស
  - ៦៤០៣៣: រង្វាន់
- ជំពូក ៦០ (ការទិញ)
  - ៦០០២១: សម្ភារៈការិយាល័យ
  - ៦០០៣៥: ពូជសត្វ
  - ៦០០៥១: សម្ភារៈ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា
  - ៦០០៥៤: សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន
  - ៦០០៥៥: សម្ភារៈ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា
  - ៦០០៦១: អគ្គិសនី
  - ៦០០៦២: ទឹក
  - ៦០០៧២: សម្ភារៈបរិក្ខារពេទ្យ
- ជំពូក ៦១ (សេវាកម្ម)
  - ៦១០៥២: ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ
  - ៦១០៥៣: ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ
  - ៦១០៥៥: ការថែទាំប្រព័ន្ធធារាសាស្ត្រ
  - ៦១១៤១: សោហ៊ុយប្រៃសណីយ៍
  - ៦១១៤២: សោហ៊ុយទូរគមនាគមន៍
  - ៦១១៤៨: សោហ៊ុយទូរគមនាគមន៍ផ្សេងៗ
- ជំពូក ៦២ (អត្ថប្រយោជន៍សង្គម)
  - ៦២០២២: ឱសថ

- ៦២០២៤ : ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ
- ៦២០២៨ : ជំនួយសង្គមផ្សេងៗ
- ៦២០៣១ : ឧបត្ថម្ភសហគមន៍ និងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គម

▪ **ជំពូក ៦៥ (ឧបត្ថម្ភធន)**

- ៦៥០៧២ : ការចូលរួមក្នុងការអនុវត្តគម្រោងមូលនិធិទ្រទ្រង់ថវិកា។

**ប្រការ១០.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងដាក់ចេញសារាចរបន្ថែមតាមការចាំបាច់លើការធ្វើប្រតិភូកម្មសិទ្ធិអំណាច ក្នុងការបង្វែរឥណទានថវិកា។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ កើត ខែ ផល្គុន ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

***កន្លែងទទួល៖***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *រដ្ឋបាលរាជធានី ខេត្ត*
- *ដូចប្រការ ១២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*